**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

លេខៈ ២០៣៩ មស.អសរ

# សេចក្តីសម្រេច
## ស្តីពី
## ការប្រឡងប្រជែងជ្រើសរើសសិស្សមន្ត្រីជាន់ខ្ពស់លើកទី១០

## រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ត្រាស់បង្គាប់ឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ត្រាស់បង្គាប់ឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១០៦២ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣ ត្រាស់បង្គាប់ផ្ទេរសាលាភូមិន្ទរដ្ឋបាល ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/១៩៥ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/៤០/០៤៩៥ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតសាលាភូមិន្ទរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្របក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១៩៧ អនក្របក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីលក្ខន្តិកៈរបស់សាលាភូមិន្ទរដ្ឋបាល



អាសយដ្ឋានៈ (កែងផ្លូវម៉ៃដាលេខ២០០៤) ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ទូរស័ព្ទ.ទូរសារ(៨៥៥) ២៣ ៨៦៦ ៥០១

- បានឃើញអនុក្រឹត្យលេខ៥៩ អនក្រ.តក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ ស្តីពីការលើកលែងលក្ខខណ្ឌអាយុ និងការកំណត់អាយុបេក្ខជនចូលរួមប្រឡងប្រជែងជ្រើសរើសចូលក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិល
- យោងតាមស្មារតីនៃអង្គប្រជុំក្រុមប្រឹក្សាសាលា ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧

## សម្រេច

**ប្រការ១ ._**

អនុញ្ញាតឱ្យបើកការបណ្តុះបណ្តាលសិស្សមន្ត្រីជាន់ខ្ពស់លើកទី១០ ចំនួន ៦០នាក់ (ជំនាញរដ្ឋបាលទូទៅ ២០នាក់ ជំនាញសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ២០នាក់ និងជំនាញទំនាក់ទំនងអន្តរជាតិ ២០នាក់) នៅសាលាភូមិន្ទរដ្ឋបាល ដោយត្រូវធ្វើការជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ និងនិស្សិត។

កាលបរិច្ឆេទប្រឡងប្រជែងនឹងប្រព្រឹត្តទៅនៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៧។

**ប្រការ២ ._**

បេក្ខជនត្រូវជ្រើសរើសជំនាញមួយ ក្នុងចំណោមជំនាញទាំងបី នៅពេលដាក់ពាក្យសុំប្រឡងប្រជែងសិស្សមន្ត្រីជាន់ខ្ពស់លើកទី១០។

**ប្រការ៣ ._**

បេក្ខជនត្រូវបំពេញលក្ខខណ្ឌសម្រាប់ការជ្រើសរើសដូចខាងក្រោម៖

- **កម្រិតសញ្ញាបត្រ៖** បេក្ខជនជាមន្ត្រីរាជការ ឬនិស្សិត ត្រូវមានសញ្ញាបត្រទាបបំផុតបរិញ្ញាបត្រ ឬសញ្ញាបត្រដែលមានតម្លៃស្មើ។
- **លក្ខខណ្ឌអាយុ៖**
  . បេក្ខជនជាមន្ត្រីរាជការនិងបេក្ខជនដែលមានកម្រិតបណ្តុះបណ្តាលចាប់ពីសញ្ញាបត្រថ្នាក់បណ្ឌិតឡើងទៅ ត្រូវបានលើកលែងលក្ខខណ្ឌអាយុ
  . បេក្ខជនដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឬសមមូល ត្រូវមានអាយុច្រើនបំផុត ៤០(សែសិប)ឆ្នាំ គិតមកដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៧
  . បេក្ខជនដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រឬសមមូល ត្រូវមានអាយុច្រើនបំផុត ៣៥(សាមសិបប្រាំ) ឆ្នាំ គិតមកដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៧។
- **លិខិតថ្កោលទោស៖** ត្រូវមានលិខិតថ្កោលទោស ចេញដោយក្រសួងយុត្តិធម៌ នៅក្រោយពេលប្រឡងជាប់ជាស្ថាពរ។
- **លិខិតពិនិត្យសុខភាព៖** ត្រូវមានលិខិតពិនិត្យសុខភាព ចេញដោយនាយកដ្ឋានពេទ្យការងារនៅក្រោយពេលប្រឡងជាប់ជាស្ថាពរ។

បញ្ជីបេក្ខជនដែលអនុញ្ញាតឲ្យចូលធ្វើវិញ្ញាសាប្រឡងប្រជែង ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រសួងមុខងារសាធារណៈ។

**ប្រការ៤ ._**

វិញ្ញាសាប្រឡងប្រជែងរួមមាន៖ វិញ្ញាសាសរសេរ និងវិញ្ញាសាសួរផ្ទាល់មាត់។

**ក- វិញ្ញាសាសរសេរលើកទី១ មាន ៖**

| | | |
|---|---|---|
| ១- សំណួរពហុចម្លើយ | "រយៈពេល ២ម៉ោង" | មេគុណ ១ |
| ២- ភាសាបារាំង ឬអង់គ្លេស | "រយៈពេល ១ម៉ោង៣០នាទី" | មេគុណ ១ |

មានតែបេក្ខជនដែលបានប្រឡងជាប់វិញ្ញាសាសរសេរលើកទី១តែប៉ុណ្ណោះ ដែលនឹងត្រូវអនុញ្ញាតឲ្យចូលរួមប្រឡងវិញ្ញាសាសរសេរលើកទី២ ។

ខ- វិញ្ញាសាសរសេរលើកទី២ មាន ៖

| | | |
|---|---|---|
| ១- អធិប្បាយពាក់ព័ន្ធនឹងចំណេះដឹងទូទៅ | "រយៈពេល ៣ម៉ោង" | មេគុណ ៣ |
| ២- ដោះស្រាយបញ្ហាតាមករណីសិក្សា | "រយៈពេល ២ម៉ោង" | មេគុណ ១ |
| ៣- ជំនាញ | "រយៈពេល៣ម៉ោង" | មេគុណ ៣ |

បេក្ខជនត្រូវជ្រើសរើសវិញ្ញាសាជំនាញរបស់ខ្លួនដូចខាងក្រោម៖

- សេដ្ឋកិច្ច-ហិរញ្ញវត្ថុ (សម្រាប់ជំនាញសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)
- រដ្ឋបាលសាធារណៈ (សម្រាប់ជំនាញរដ្ឋបាលទូទៅ)
- នីតិអន្តរជាតិសាធារណៈ និងទំនាក់ទំនងអន្តរជាតិ (សម្រាប់ជំនាញ ទំនាក់ទំនងអន្តរជាតិ)

មានតែបេក្ខជនដែលបានប្រឡងជាប់វិញ្ញាសាសរសេរលើកទី២តែប៉ុណ្ណោះ ដែលនឹងត្រូវអនុញ្ញាតឲ្យចូលរួមប្រឡងវិញ្ញាសាសួរផ្ទាល់មាត់។

**គ- វិញ្ញាសាសួរផ្ទាល់មាត់៖** ធ្វើមូលវិចារណ៍លើបុគ្គលិកលក្ខណៈ និងលើហេតុប្បទ្ទេសរបស់បេក្ខជន ក្នុងពេលតែមួយសម្រាប់ រយៈពេលពី «១៥នាទីទៅ៣០នាទី» មេគុណ៣

**ប្រការ៥ ..**

ក្រោយការប្រឡងប្រជែង ប្រធានគណៈមេប្រយោគត្រូវធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាសាលា។ របាយការណ៍នេះ នឹងត្រូវបញ្ជូនទៅក្រសួងមុខងារសាធារណៈ។

**ប្រការ៦ ..**

ការទទួលស្គាល់ជាសិស្សមន្ត្រីជាន់ខ្ពស់ សាលាភូមិន្ទរដ្ឋបាលត្រូវធ្វើដោយសេចក្ដីសម្រេចរបស់ក្រសួងមុខងារសាធារណៈ។ ក្នុងកំឡុងពេលសិក្សា សិស្សត្រូវបានផ្ដល់ប្រាក់ឧបត្ថម្ភប្រចាំខែតាមការកំណត់របស់រាជរដ្ឋាភិបាល។ បេក្ខជនជាមន្ត្រីរាជការ ដែលបានប្រឡងជាប់ជាស្ថាពរនៅសាលាភូមិន្ទរដ្ឋបាល ត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅមុខតំណែង ឬក្របខណ្ឌ ដោយរក្សាបៀវត្សមូលដ្ឋាននៅអង្គភាពដើម មុនពេលចូលរៀននៅសាលាភូមិន្ទរដ្ឋបាល។

សិស្សមន្ត្រីជាន់ខ្ពស់ត្រូវទទួលការបណ្ដុះបណ្ដាលរយៈពេល ២ឆ្នាំ។

**ប្រការ៧ ..**

ក្រុមប្រឹក្សាសាលាភូមិន្ទរដ្ឋបាល នាយកសាលាភូមិន្ទរដ្ឋបាល អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ និងអគ្គនាយកនៃអគ្គនាយកដ្ឋានពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០១៧ 

**រដ្ឋមន្ត្រី**

**ពេជ្រ ប៊ុនធិន**

**ចម្លងជូន ៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច លោកជំទាវ ឯកឧត្ដម ឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ
- សមាជិកក្រុមប្រឹក្សាសាលា
- ដូចប្រការ ៧
- ឯកសារ កាលប្បវត្តិ